Civil society Links and Empowerment for Socially Inclusive Development in Ratanakiri



# គោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់ខ្សែសង្វាក់តម្លៃស្រូវ ក្នុងខេត្តរតនគិរី, ប្រទេសកម្ពុជា

**ILS LEDA**

ការសិក្សានេះត្រូវបានចងក្រងដោយអ្នកជំនាញរបស់ ILSLEDA ក្នុងក្របខ័ណ្ឌនៃគម្រោង "CLESIDRA: ការចងបណ្ដាញ និងការពង្រឹងសង្គមស៊ីវិលសម្រាប់ការអភិវឌ្ឍន៍សង្គមបែបបរិយាបន្នក្នុងខេត្តរតនគិរី" ដែលសហការផ្ដល់មូលនិធិដោយសហភាពអឺរ៉ុប។

*ខែវិច្ឆិកា ឆ្នាំ២០២៤*

FELCOSUMBRIA Associazione di Comuni per lo Sviluppo Sostenibile

## ជំពូកទី 5. គោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយការប្រកួតប្រជែង និងបរិយាប័ន្ន (ការរួមបញ្ចូល)

### ៥.១. វិធីសាស្ត្រក្នុងការបរិយាយលម្អិតនៃគោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ ស្រូវ

វិធីសាស្ត្រ **រេស្កូ**(RESCO) សម្រាប់ការបកស្រាយលម្អិតនៃគោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្មសាច់គោ និងគោទឹកដោះគោ ប្រើប្រាស់ធាតុចូលនៃដំណើរការវាយតម្លៃ **រេស្កូ**(RESCO) (ការសម្ភាសន៍), ប្រើប្រាស់ទិន្នន័យបានពីលទ្ធផលនៃការវិភាគការស្រាវជ្រាវ និងពីការពិគ្រោះយោបល់ជាមួយអ្នកជំនាញ និងចាត់ថ្នាក់ការរកឃើញនៅទាំងអស់នេះក្នុងការអន្តរាគមន៍។

ធាតុចូលសំដៅទៅលើសូចនាករផលប៉ះពាល់នៃអថេរនីមួយៗដែលឆ្លើយតបនឹងកត្តានីមួយៗ ប្រសិនបើវាវិជ្ជមាន (ចំណុចខ្លាំង) ឬអវិជ្ជមាន (ចំណុចខ្សោយ) ដូចដែលបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម។




សកម្មភាពយុទ្ធសាស្ត្រសម្រាប់ឆ្លើយតបគួរត្រូវបានធ្វើឡើងដើម្បី៖

a. រក្សាចំណុចខ្លាំងក្នុងរយៈពេលយូរ
b. ដកចំណុចខ្សោយចេញ ព្រោះវាតំណាងឲ្យឧបសគ្គដល់ការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្ម។

ទីបំផុត វិធីសាស្ត្រ **រេស្កូ**(RESCO) ប្រើក្បួនដោះស្រាយសាមញ្ញមួយសម្រាប់ការទាញយកសកម្មភាពយុទ្ធសាស្ត្រសម្រាប់ "អថេរ" នីមួយៗដែលឆ្លើយតបទៅនឹង "កត្តា" ផ្សេងៗ។

រូបមន្តមានដូចខាងក្រោម៖

$Sa = f(V_{i,j}, Fa_n)$

*$Sa$= សកម្មភាពយុទ្ធសាស្ត្រ*

*$V_{i,j}$= អថេរ "i" នៃសមាសភាគ "j"*

*$Fa_n$= កត្តា "n"*

## ៥.២. ពីសក្ដានុពល និងតម្រូវការ ទៅជាសកម្មភាព

សក្ដានុពល និងតម្រូវការសំខាន់ៗដៅទៅលើកត្តានីមួយៗ និងអថេរនៃខ្សែសង្វាក់ផលិតកម្ម ស្រូវ ត្រូវបានបង្ហាញនៅក្នុងជំពូកទី 4 ។

ដំណើរការពីការអនុវត្តសកម្មភាពយុទ្ធសាស្ត្រ ទៅជាតម្រូវការដែលបានរៀបរាប់ខាងលើត្រូវបានគេមើលឃើញទុកជាមុន៖

1. កំណត់សកម្មភាពបុគ្គលសម្រាប់អថេរនីមួយៗ
2. ចាត់ថ្នាក់ ឬបែងចែកសកម្មភាពបំពេញបន្ថែមជាក្រុម ឬតាមក្រុម
3. លុបបំបាត់ការចម្លង (អ្វីដែលដូចគ្នា ឬចម្លងចេញពីគ្នា)
4. រួមបញ្ចូលសកម្មភាពនីមួយៗក្នុងការឆ្លើយតបនឹង "ការអនុវត្តយុទ្ធសាស្ត្រ"

អាស្រ័យហេតុនេះ ការវាយតម្លៃដោយប្រើវិធីសាស្ត្រ **រេស្កូ**(RESCO) ក៏បានផ្ដល់នូវសកម្មភាពយុទ្ធសាស្ត្រយ៉ាងតិចចំនួនបីផងដែរ ដូចជា៖

a. អភិបាលកិច្ច
b. ការកសាងសមត្ថភាព
c. ប្រព័ន្ធសេវាកម្ម

ដោយពិចារណាលើអាទិភាពដែលកើតចេញពីការវិភាគស្ថានភាព និងសក្ដានុពលនៃខ្សែសង្វាក់ផលិតកម្ម ស្រូវ និងគោលដៅរបស់គម្រោង **ខ្លេស៊ីដ្រា** (CLESIDRA) សកម្មភាពយុទ្ធសាស្ត្រទាំងនេះត្រូវបានចាត់ថ្នាក់ជាក្រុម(តាមក្រុម) ទៅតាមអាទិភាពទាំងបីកម្រិតរួមមាន៖

- **អាទិភាពលេខ ១**៖ សកម្មភាពដែលឆ្លើយតបទៅនឹងគោលបំណង និងសំណើនៃផែនការការងាររបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) (សូមមើលប្រអប់ទី 1) ហើយក្នុងពេលជាមួយគ្នានេះ វាក៏ឆ្លើយតបទៅនឹង "អាទិភាពខ្ពស់ (HP)" ដែលបង្ហាញដោយក្រុម **រេស្កូ**(RESCO)
- **អាទិភាពលេខ ២**៖ សកម្មភាពដែលឆ្លើយតបទៅនឹង "អាទិភាពខ្ពស់ (HP)" ដែលបង្ហាញដោយក្រុម RESCO ប៉ុន្តែមិនត្រូវបានមើលឃើញដោយគម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នោះទេ ហើយវានឹងតម្រង់ទិសផែនការបីឆ្នាំរបស់ [ វេទិកា**ផ្លាសិដ** (PLASED), គណៈកម្មាធិការខ្សែសង្វាក់ផលិតកម្មស្រូវ និង ប្រព័ន្ធសេវាកម្មទូលំទូលាយ កុស្ស(COSS)]
- **អាទិភាពលេខ ៣**៖ សកម្មភាពឆ្លើយតបទៅនឹង "អាទិភាពមធ្យម (MP)" ដែលបង្ហាញដោយក្រុម **រេស្កូ** (RESCO)

**ប្រអប់ទី ១៖ ផែនការការងារគម្រោង ខ្លេស៊ីដ្រា**(CLESIDRA)

WP - **ការធ្វើឲ្យប្រសើឡើងនូវជំនាញរបស់សង្គមស៊ីវិល អ្នកផលិត និងអាជ្ញាធរ ទៅលើកិច្ចសន្ទនាពហុភាគី, ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម**

A1.1 ការកសាងសមត្ថភាពសម្រាប់សង្គមស៊ីវិលស្ដីពីការចូលរួមយ៉ាងសកម្មក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត និងកិច្ចសន្ទនាពហុភាគី។

DRAFT

A1.2 វគ្គបណ្តុះបណ្តាលស្តីពី ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និង ការប្រកួតប្រជែងនិងនិរន្តរភាពនៃខ្សែសង្វាក់ផលិតកម្ម។

A1.3 វគ្គបណ្តុះបណ្តាល និងការគាំទ្រដើម្បីបង្កើនសមត្ថភាពរបស់សង្គមស៊ីវិល (អភិបាលកិច្ចផ្ទៃក្នុង ផលប៉ះពាល់ ការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ ការតស៊ូមតិ ការបង្កើតគម្រោង និងការគ្រប់គ្រងគម្រោង)

A.1.4 វគ្គបណ្តុះបណ្តាល និងការផ្តល់ជំនួយបច្ចេកទេសដល់សង្គមស៊ីវិលលើបច្ចេកទេស/វិធីសាស្ត្រផលិតកម្មប្រកបដោយនិរន្តរភាព ការអភិរក្សធនធានធម្មជាតិ និងសន្តិសុខរបស់កសិករខ្នាតតូច {រួមទាំងសិទ្ធិកាន់កាប់(ដីធ្លី)}

WP2 - **ការបង្កើតវេទិកា ផ្លាសិដ** (PLASED) **(វេទិកាសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព)**

A2.1៖ ការផ្តល់ជំនួយបច្ចេកទេសក្នុងការរចនា និងការចាប់ផ្តើមវេទិកា **ផ្លាសិដ** (PLASED)

A2.2: ការចាប់ផ្តើមនៃវេទិកា **ផ្លាសិដ** (PLASED) និងការអនុវត្តសកម្មភាពយុទ្ធសាស្ត្រ

A2.3៖ ការបង្កើត ការបោះពុម្ពផ្សាយ និងចរាចរកូនសៀវភៅស្តីពី បទពិសោធន៍របស់វេទិកា**ផ្លាសិដ** (PLASED)

WP3 - **ការបរិយាយលម្អិតដោយមានការចូលរួមនៃយុទ្ធសាស្ត្រ**(STRAT) **សម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្មប្រកបដោយការប្រកួតប្រជែង បរិយាប័ន្ន និរន្តរភាព និងភាពធន់។**

WP4 - **ការបង្កើត ប្រព័ន្ធសេវាកម្មទូលំទូលាយ** កុស្ស(COSS)

A4.1 ការធ្វើផែនទី និងការវិភាគអ្នកផ្តល់សេវា/ហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តរតនគិរី

A4.2 ជំនួយបច្ចេកទេសសម្រាប់ការរចនា ប្រព័ន្ធសេវាកម្មទូលំទូលាយ កុស្ស(COSS)

A4.3 ការកសាងសមត្ថភាព និងជំនួយបច្ចេកទេសដល់ការចាប់ផ្តើម កុស្ស(COSS)

A4.4 សិក្ខាសាលាពង្រឹងសមត្ថភាព ដើម្បីបង្កើនជំនាញរបស់អ្នកផ្តល់សេវាកម្ម និងដោះស្រាយបញ្ហាគម្លាតនៃប្រព័ន្ធសេវាកម្ម

A4.5 ការចាប់ផ្តើម កុស្ស(COSS) និងការផ្តល់ជំនួយហិរញ្ញវត្ថុដល់អ្នកប្រើប្រាស់ កុស្ស(COSS) ដែលបានជ្រើសរើស (ជំនួយផ្នែកហិរញ្ញវត្ថុដល់ភាគីទីបី)

**ចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្ម ស្រូវ**

លទ្ធផលដំបូងនៃការវាយតម្លៃប្រើប្រាស់វិធីសាស្ត្រ **រេស្កូ** (RESCO) គឺការកំណត់ចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្មស្រូវដែលត្រូវសម្រេចនៅឆ្នាំ 2030។

ចក្ខុវិស័យនេះមាន ការបង្កើនទីផ្សារជាតិ(ទីផ្សារក្នុងស្រុក)ចំនួន 30% និងទីផ្សារអន្តរជាតិចំនួន 10% ដោយពឹងផ្អែកលើអត្ថប្រយោជន៍ប្រកួតប្រជែងដែលផ្តល់ដោយដំណើរការផលិតតាមបែបសរីរាង្គ(បែបធម្មជាតិ) និងសមត្ថភាពរបស់កសិករក្នុងការធ្វើឲ្យរុក្ខជាតិធន់នឹងជំងឺ ហើយក៏អរគុណចំពោះប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ និងចំណេះដឹងបែបប្រពៃណី។ .

ជាក់ស្តែង ស្រូវក្នុងខេត្តរតនគិរី អាចត្រូវបានចាត់ទុកថាជាស្រូវ/អង្ករសរីរាង្គដ៏ល្អបំផុតរបស់កម្ពុជា ដែលដាំដុះដោយដៃដ៏ឈ្លាសវៃនៃប្រពៃណីបុរាណក្នុងស្រុក។

## ៥.៣. គោលការណ៍ណែនាំជាយុទ្ធសាស្ត្រ និងផែនការសកម្មភាពលម្អិត

### អាទិភាពលេខ ១

**AM - ខ្សែសង្វាក់តម្លៃកម្រឹតច្រើន**

**AM1.1. អភិបាលកិច្ច**

**AM1.11៖** បង្កើតវេទិកា **ផ្លាសិដ**(PLASED) (វេទិកាសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព) ដែលជាយន្តការសម្រាប់ពង្រឹងការសន្ទនាក្នុងសង្គម និងការរក្សាបាននូវអត្ថប្រយោជន៍ប្រកួតប្រជែង និងការបង្កើតការងារ តាមរយៈ៖

a. ការផ្តល់ជំនួយបច្ចេកទេសក្នុងការរចនា និងការចាប់ផ្តើមវេទិកា **ផ្លាសិដ**(PLASED)
b. គាំទ្រសកម្មភាពអាទិភាព ដូចជា៖
   b1: ការព្រាងយុទ្ធសាស្ត្រទីផ្សារក្នុងតំបន់
   b2: បញ្ចុះបញ្ចូលរដ្ឋាភិបាលសម្រាប់ការកែលម្អការអនុវត្តផែនការរបស់រដ្ឋាភិបាល និងគាំទ្រសហគ្រាសធុនតូចនិងមធ្យម (SMMEs) ដែលចង់រីកចម្រើន និងមានលក្ខណៈផ្លូវការ។
c. គាំទ្រការកសាងសម្ព័ន្ធភាពជាមួយតួអង្គជាតិ និងអន្តរជាតិផ្សេងៗ។
d. ការបោះពុម្ព និងផ្សព្វផ្សាយកូនសៀវភៅស្តីពី បទពិសោធន៍របស់វេទិកា **ផ្លាសិដ** (PLASED)

សកម្មភាពនេះស្ថិតនៅក្នុងផែនការការងាររបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) ក្នុងចំណុច WP2។

**AM1.2. សេវាកម្ម**

**AM1.21** បង្កើតប្រព័ន្ធសេវាកម្មទូលំទូលាយ COSS សម្រាប់ការផ្តល់សេវាសេដ្ឋកិច្ចសង្គមប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល តាមរយៈ៖

a. ការធ្វើផែនទី និងការវិភាគអ្នកផ្តល់សេវា/ហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តរតនគិរី
b. ជំនួយបច្ចេកទេសសម្រាប់ការរចនា ប្រព័ន្ធសេវាកម្មទូលំទូលាយ កុស្ស(COSS)
c. ការកសាងសមត្ថភាព និងជំនួយបច្ចេកទេសដល់ការចាប់ផ្តើម កុស្ស(COSS)
d. ការចាប់ផ្តើម កុស្ស(COSS) និងការផ្តល់ជំនួយហិរញ្ញវត្ថុដល់អ្នកប្រើប្រាស់ កុស្ស(COSS) ដែលបានជ្រើសរើស (ជំនួយផ្នែកហិរញ្ញវត្ថុដល់ភាគីទីបី)

សកម្មភាពនេះស្ថិតនៅក្នុងផែនការការងាររបស់គម្រោង ខ្លេស៊ីដ្រា(CLESIDRA) ក្នុងចំណុច WP4។

AM1.22៖ ធ្វើឲ្យប្រសើរឡើងនូវសេវាកម្មអាជីវកម្ម និងលទ្ធភាពទទួលបានសេវាកម្មទាំងនោះ ដោយផ្តល់អាទិភាពដល់សេវាកម្មដូចខាងក្រោម៖

a. សេវាបច្ចេកទេស រដ្ឋបាល និងសេវាកម្មអង្គភាព ឬស្ថាប័ន
b. ការធ្វើទីផ្សារ/ពាណិជ្ជកម្ម
c. គាំទ្រក្នុងការអភិវឌ្ឍន៍សហករណ៍ កិច្ចសហប្រតិបត្តិការ/បណ្តាញទំនាក់ទំនង
d. ការគាំទ្រក្នុងការអភិវឌ្ឍន៍សម្ព័ន្ធភាព/សមាគម

សកម្មភាពនេះស្ថិតនៅក្នុងផែនការការងាររបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) ក្នុងចំណុច WP4 (A4.4)

AM1.3៖ **ការកសាងសមត្ថភាព**

AM1.31៖ កសាងសមត្ថភាពលើការគ្រប់គ្រងអាជីវកម្ម និងការធ្វើផែនការអាជីវកម្ម ដែលមានប្រយោជន៍ផងដែរសម្រាប់ស្នើសុំសំណើថវិកា និងឥណទាន។

សកម្មភាពនេះស្ថិតនៅក្នុងផែនការការងាររបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) ក្នុងចំណុចWP1 (A1.4)

A1.1 **អភិបាលកិច្ច**

A1.11៖ បង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្ម ស្រូវ ដោយផ្អែកលើក្រុមស្នូល និងជាក្រុមរងនៃវេទិកា ផ្លាសិដ(PLASED) និងសម្របសម្រួលការផ្តួចផ្តើមគំនិតរួមគ្នា ដើម្បីរក្សាបាននូវអត្ថប្រយោជន៍ប្រកួតប្រជែង (លក្ខណៈសរីរាង្គនៃពូជជាក់លាក់ដែលប្រើនៅក្នុងខេត្តរតនគិរី ដូចជា ផ្ការំដួល នាងអំ ក្រចកជាស និងពូជបុរាណ/ពូជប្រពៃណី) ការការពារប្រព័ន្ធអេកូឡូស៊ី ធ្វើឲ្យប្រសើឡើងនូវទម្លាប់របស់ប្រជាជន ជំរុញការផលិតតាមបែបសរីរាង្គ (ធម្មជាតិ) និងបង្កើតឲ្យមានសេដ្ឋកិច្ចបៃតង។

សកម្មភាពនេះស្ថិតនៅក្នុងផែនការការងាររបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) ក្នុងចំណុច WP3 និង WP2 (A2.2)

A1.12៖ ការសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងថ្នាក់ជាតិ តាមរយៈការបង្កើតក្រុមការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរសាធារណៈពាក់ព័ន្ធផ្សេងទៀតសម្រាប់៖

a. ការណែនាំអំពីការលើកទឹកចិត្តថ្នាក់ជាតិ ឬវិធានការណ៍ដើម្បីគាំទ្រខ្សែសង្វាក់ផលិតកម្ម ជាពិសេសការកាត់បន្ថយតម្លៃឧបករណ៍ (ម៉ាស៊ីនភ្ជួររាស់ ម៉ាស៊ីនច្រូតកាត់ ម៉ាស៊ីនកិនស្រូវ ម៉ាស៊ីនសម្ងួត ម៉ាស៊ីនវេចខ្ចប់, ការផ្គត់ផ្គង់ឧបករណ៍ និងគ្រឿងម៉ាស៊ីន, ការផ្គត់ផ្គង់សម្រាប់ការវេចខ្ចប់ -ប្រអប់ ថង់) តាមរយៈការបង់ពន្ធត្រឹមត្រូវ និងដោយកាត់បន្ថយនីតិវិធីការិយាធិបតេយ្យ ។
b. ការកែលម្អ ឬធ្វើឲ្យប្រសើឡើងនូវប្រព័ន្ធធារាសាស្ត្រ និង/ឬណែនាំការលើកទឹកចិត្តក្នុងការសាងសង់ប្រព័ន្ធធារាសាស្ត្រនៅគ្រប់ស្រុកទាំងអស់នៃខេត្តរតនគិរី ដើម្បីឲ្យកសិករអាចធ្វើស្រែប្រាំងបានផងដែរនៅក្នុងរដូវប្រាំង។
c. ការជំរុញការលើកទឹកចិត្តត្រឹមត្រូវ និងការគាំទ្រផ្នែកហិរញ្ញវត្ថុ/បច្ចេកទេសដល់ការរីកចំរើននៃសេដ្ឋកិច្ចបៃតង កើតចេញពីដំណើរការខ្សែសង្វាក់ផលិតកម្ម។ ជាពិសេស ការផលិតតាមបែបសរីរាង្គ(បែបធម្មជាតិ) ការផលិតជី និងថ្នាំសម្លាប់សត្វល្អិត/ថ្នាំការពារជំងឺ តាមបែបធម្មជាតិ។ ការអនុវត្តប្រកបដោយនិរន្តរភាពនៃការគ្រប់គ្រងសំណល់; ការធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃគោលនយោបាយ និងបទប្បញ្ញត្តិសាធារណៈស្តីពីនិរន្តរភាពបរិស្ថាន ការកាត់បន្ថយការបំពុល (ខ្យល់ ទឹក ដី និងសំឡេង) ការកំណត់កម្រិតការបំភាយឧស្ម័ន និងការបំពុលដោយការប្រើប្រាស់ប្រភពថាមពល។ ការធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃគោលនយោបាយដែលអនុគ្រោះដល់ការសម្រេចបាននូវបរិស្ថានស្អាត; ការប្រើប្រាស់ថាមពលកកើតឡើងវិញក្នុងវិស័យផលិតកម្ម (មិនត្រឹមតែប្រើប្រាស់នៅក្នុងផ្ទះ) និងការប្រើប្រាស់ទឹកកែច្នៃឡើងវិញ។

សកម្មភាពនេះស្ថិតនៅក្នុងផែនការការងាររបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) ក្នុងចំណុច WP2 (A2.2)។

DRAFT

A1.13៖ ការសម្របសម្រួលពាណិជ្ជកម្មរួមមាន៖

a. ជំរុញការលក់ជាសមូហភាព(លក់រួមគ្នា) ដើម្បីបង្កើនអំណាចចរចា
b. សម្របសម្រួលការរៀបចំគំនិតផ្តួចផ្តើមប្រចាំឆ្នាំយ៉ាងហោចណាស់ 1 ដង (ពិព័រណ៍ ពិធីបុណ្យ ព្រឹត្តិការណ៍វប្បធម៌ ។ល។) សម្រាប់ការផ្សព្វផ្សាយផលិតផលស្រូវដែលគាំទ្រដល់ឱកាសនៃការរៃអង្គាសប្រាក់ (ឱកាសពីទីភ្នាក់ងារអន្តរជាតិ ការឧបត្ថម្ភ ការផ្តល់មូលនិធិ និងទំនួលខុសត្រូវសង្គមរបស់អាជីវកម្ម)។

សកម្មភាពនេះស្ថិតនៅក្នុងផែនការការងាររបស់គម្រោង ខ្លេស៊ីដ្រា(CLESIDRA) ក្នុងចំណុច WP2 (A2.2)។

## A1.2 **ការកសាងសមត្ថភាព**

A1.21៖ ការធ្វើឲ្យប្រសើរឡើងនូវជំនាញវិជ្ជាជីវៈ អាចធ្វើទៅបានតាមរយៈគំនិតផ្តួចផ្តើមដូចជា "សាកលវិទ្យាល័យ" និងការបង្ហាញពីការអនុវត្តប្រកបដោយភាពច្នៃប្រឌិត តាមរយៈសកម្មភាពបណ្តាញ ដោយយោងជាពិសេសទៅលើ៖

a. សមត្ថភាពបច្ចេកទេសក្នុងការជំរុញការផលិតពូជដាក់លាក់៖ ផ្ការំដួល នាងអំ ក្រចកជាស និងពូជបុរាណ/ប្រពៃណី និងរក្សាលក្ខណៈសរីរាង្គ ព្រោះពួកវាធន់នឹងសត្វល្អិត និងជំងឺ ងាយស្រួលដាំដុះ និងថែទាំ ហើយអាចដាំដុះបានលើដីគ្រប់ប្រភេទ និងគ្រប់ទីកន្លែងក្នុងខេត្តរតនគិរី។
b. របៀបផលិតផលិតផលស្រូវ និងផលិតផលកែច្នៃពីស្រូវដូចជា៖

- ស្រា (ស្រាស ឬស្រាថ្នាំ) និងផលិតផលដែលកែច្នៃចេញពីកាកសំណល់ផលិតកម្មស្រូវ ដូចជាកម្ទេចអង្ករដែលត្រូវបានប្រើជាគ្រឿងផ្សំសម្រាប់ផលិតស្រាបៀរ។
- កម្ទេចអង្ករ ដែលប្រើក្នុងឧស្សាហកម្មម្ហូបអាហារសម្រាប់ផលិតម្សៅ ដែលផលិតជាអាហារដែលទទួលបានពីអង្ករ ដូចជាម្សៅ នំជុត ប៉ាស្តា និងភេសជ្ជៈ ម្សៅប្រើប្រាស់ធ្វើចំណីសត្វ។
- ប្រេងកន្ទក់(ផលិតចេញពីកន្ទក់ ឬអង្ករ) គឺជាប្រេងបន្លែដែលមានគុណភាពខ្ពស់សម្រាប់ចម្អិនអាហារ ឬបរិភោគ។
- ចំបើង/ អង្កាម៖ ធ្វើជាពូកឬកន្លែងដេកសម្រាប់សត្វ, យកដាក់ដំណាំ, ធ្វើថូ និងធុង, ធ្វើជាម្នាងសិលា ឬសមាសធាតុសម្រាប់សង់អគារ (ដោយលាយជាមួយសម្ភារៈ/សមាសធាតុផ្សេងទៀត)
- អង្កាម/កន្ទក់៖ ចំណីសត្វ និងជីវឧស្ម័នសម្រាប់ផលិតថាមពល។
- អង្កាម៖ ជាតុចូលប្រើជាឥន្ធនៈនៅក្នុងរោងចក្រ, ធ្វើជាពូកឬកន្លែងដេកសម្រាប់សត្វ ជាពិសេសគោក្របី និងបសុបក្សី(មាន់ ទា...), ឥន្ធនៈរឹង (ឧទាហរណ៍ ដុំធ្យូងអនាម័យ), ផេះអង្កាមដែលនៅសល់បន្ទាប់ពីឆេះ ឬដុត។

សកម្មភាពនេះស្ថិតនៅក្នុងផែនការការងាររបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) ក្នុងចំណុច WP1 (A1.2)

A1.22៖ ការធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់សហគ្រិន ដូចជា៖

a. ការគ្រប់គ្រងអាជីវកម្ម
b. សមត្ថភាពចរចា
c. ការផ្តល់ហិរញ្ញប្បទានគម្រោង ឧទាហរណ៍ សមត្ថភាពអនុញ្ញាតឲ្យសម្រេចបាននូវលក្ខខណ្ឌសម្រាប់សិទ្ធិទទួលបាន និងលទ្ធភាពក្នុងការប្រើប្រាស់មូលនិធិពីស្ថាប័នឯកជន និងសាធារណៈ(ទាំងជាតិ និងអន្តរជាតិ)

DRAFT

d. ការធ្វើឲ្យប្រសើរឡើងនូវសហករណ៍ក្នុងការទទួលបានហិរញ្ញប្បទាន និងថវិកា ដើម្បីបង្កើនបរិមាណស្រូវដែលត្រូវទិញ
e. អាជីវកម្មដែលមានលក្ខណៈជាសេដ្ឋកិច្ចរាងជារង្វង់ ដូចជា៖ ផលិតកម្មដែលមិនប៉ះពាល់ដល់បរិស្ថាន, ការប្រើប្រាស់សម្ភារៈដែលអាចកែច្នៃឡើងវិញបាន; ការសន្សំថាមពល និងការប្រើប្រាស់ទឹក, ការប្រើប្រាស់ថាមពលកកើតឡើងវិញ, ការអនុវត្តប្រកបដោយនិរន្តរភាពនៃការគ្រប់គ្រងសំណល់ (ប្រើប្រាស់ឡើងវិញនូវសំណល់ និងការប្រើប្រាស់ឡើងវិញនូវទឹកសំណល់ - ទឹកដែលប្រើប្រាស់ហើយ), ការប្រមូលសំរាម បែងចែកឬចាត់ថ្នាក់សំរាម ការរក្សាទុក និងការកែច្នៃឡើងវិញ។
f. ការអនុគ្រោះដល់ស្ត្រីក្នុងការចូលទៅកាន់ខ្សែសង្វាក់ផលិតកម្ម

សកម្មភាពនេះស្ថិតនៅក្នុងផែនការការងាររបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) ក្នុងចំណុច WP1 (A1.4)

A1.23៖ អនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹង (អាចតាមរយៈសន្និសីទរួម) ដើម្បីបង្កើននិរន្តរភាពបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលត្រូវបានដោះស្រាយចំពោះប្រជាជន (រួមបញ្ចូលទាំងតរិយាបទមិនបំពុល) ស្ថាប័ន (ការពេញចិត្ត និងអនុវត្តយុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើមដែលអំណោយផល/អនុគ្រោះដល់ការការពារបរិស្ថាន។) និងអ្នកផលិត (អនុវត្តការផលិតជី និងថ្នាំសម្លាប់សត្វល្អិត/ថ្នាំការពារជំងឺ តាមបែបធម្មជាតិ) ដើម្បីឲ្យពួកគេមានអាកប្បកិរិយាវិជ្ជមានក្នុងការការពារបរិស្ថានលើបញ្ហាដូចខាងក្រោម៖
a. និរន្តរភាពបរិស្ថាន ការកាត់បន្ថយការបំពុល ការកំណត់កម្រិតនៃការបំភាយឧស្ម័ន និងការបំពុលដោយការប្រើប្រាស់ប្រភពថាមពល សារៈសំខាន់នៃការការពារបរិស្ថានសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងតំបន់ និងសម្រាប់ការថែរក្សាភាពប្រកួតប្រជែងនៃខ្សែសង្វាក់ផលិតកម្ម។
b. សារៈសំខាន់នៃកសិកម្មឆ្លាតវៃ និងអត្ថប្រយោជន៍របស់វា
c. សារៈសំខាន់ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ។
d. សារៈសំខាន់នៃសេដ្ឋកិច្ចរាងជារង្វង់ ចាប់ផ្តើមពីការអនុវត្តប្រកបដោយនិរន្តរភាពនៃការគ្រប់គ្រងសំណល់ (ដូចជាការប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ)
e. ការធ្វើឲ្យប្រសើរឡើងនូវឧបករណ៍ត្រួតពិនិត្យបរិស្ថាន។

សកម្មភាពនេះស្ថិតនៅក្នុងផែនការការងាររបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) ក្នុងចំណុច WP1 (A1.1)

A1.3៖ **សេវាកម្ម**

A1.31៖ ធ្វើអោយប្រសើរឡើងនូវសេវាកម្មអាជីវកម្ម និងការចូលប្រើប្រាស់សេវាទាំងនោះ តាមរយៈការសម្របសម្រួលអ្នកផ្តល់សេវាកម្ម ជាពិសេសសេវាកម្មដូចខាងក្រោម៖
a. សេវាកម្មទីផ្សារ និងពាណិជ្ជកម្ម ដែលផ្សព្វផ្សាយពូជដែលប្រើក្នុងខេត្តរតនគិរី (ផ្ការំដួល នាងអំ ក្រចកជាស និងពូជបុរាណ/ប្រពៃណី) តាមរយៈគោលនយោបាយម៉ាកយីហោ ការផ្សាយពាណិជ្ជកម្ម ការដាក់ស្លាក តាមដាន និងការទទួលស្គាល់ដោយផ្អែកលើទីតាំងភូមិសាស្ត្រ(ឧ. ចន្ទីដាំក្នុងខេត្តរតនគិរី)។ ជាពិសេស ដូចពូជនាងអំ និងក្រចកជាសដែលពូជធន់នឹងជំងឺ។ ពិសេសទាក់ទងនឹងការធ្វើទីផ្សារជាក្រុម យន្តការតាមដាន,

ការនាំយកផលិតផលចូលក្នុងទីផ្សារអន្តរជាតិ និងការធ្វើពាណិជ្ជកម្មអន្តរជាតិនៃផលិតផលស្រូវ និងផលិតផលកែច្នៃពីស្រូវ។

b. សេវាកម្មបើក/ចាប់ផ្តើមអាជីវកម្ម ជាពិសេសសម្រាប់ការបង្កើតសហគ្រាសថ្មីសម្រាប់ផលិតផលិតផលស្រូវ និងផលិតផលកែច្នៃពីស្រូវ៖
   - ស្រា (ស្រាស ឬស្រាថ្នាំ) និងផលិតផលដែលកែច្នៃចេញពីកាកសំណល់ផលិតកម្មស្រូវ ដូចជាកម្ទេចអង្ករ ដែលត្រូវបានប្រើជាគ្រឿងផ្សំសម្រាប់ផលិតស្រាបៀរ។
   - កម្ទេចអង្ករ ដែលប្រើក្នុងឧស្សាហកម្មម្ហូបអាហារសម្រាប់ផលិតម្សៅ ដែលផលិតជាអាហារដែលទទួលបានពីអង្ករ ដូចជាម្សៅ នំដុត ប៉ាស្តា និងភេសជ្ជៈ ម្សៅប្រើប្រាស់ធ្វើចំណីសត្វ។
   - ប្រេងកន្ទក់(ផលិតចេញពីកន្ទក់ ឬអង្ករ) គឺជាប្រេងបន្លែដែលមានគុណភាពខ្ពស់សម្រាប់ចម្អិនអាហារ ឬបរិភោគ។
   - ចំបើង/ អង្កាម៖ ធ្វើជាពូកឬកន្លែងដេកសម្រាប់សត្វ, យកដាក់ដំណាំ, ធ្វើថូ និងធុង, ធ្វើជាម្នាងសិលា ឬសមាសធាតុសម្រាប់សង់អគារ (ដោយលាយជាមួយសម្ភារៈ/សមាសធាតុផ្សេងទៀត)
   - អង្កាម/កន្ទក់៖ ចំណីសត្វ និងជីវឧស្ម័នសម្រាប់ផលិតថាមពល។
   - អង្កាម៖ ជាតុចូលប្រើជាឥន្ធនៈនៅក្នុងរោងចក្រ, ធ្វើជាពូកឬកន្លែងដេកសម្រាប់សត្វ ជាពិសេសគោក្របី និងបសុបក្សី(មាន់ ទា...), ឥន្ធនៈរឹង (ឧទាហរណ៍ ដុំធ្យូងអនាម័យ), ផេះអង្កាមដែលនៅសល់បន្ទាប់ពីការឆេះ ឬដុត។

a) សេវាកម្មគាំទ្រដល់៖
   - ការទទួលបានឧបករណ៍/សម្ភារៈដែលមានប្រយោជន៍សម្រាប់ខ្សែសង្វាក់ផលិតកម្មស្រូវ ដោយធានានូវតម្លៃ និងគុណភាពល្អបំផុត
   - សេវាគាំទ្រលើប្រតិបត្តិការ និងថែទាំប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់
   - សេវាគាំទ្រឯកទេសក្នុងការបង្កើនទិន្នផល គុណភាព រួមទាំងការកាត់បន្ថយការខាតបង់ក្នុងការផលិត និងការតាមដាន

b) សេវាកម្មហិរញ្ញវត្ថុ

A1.32៖ ធ្វើឲ្យប្រសើរឡើងនូវសេវាកម្មសម្រាប់និរន្តរភាពបរិស្ថានតាមរយៈ៖
- ការបង្កើតសហគ្រាសសម្រាប់ការកែច្នៃសំណល់រឹង រាវ និងសរីរាង្គ។
- លើកកម្ពស់សេវាកម្មដំឡើង និងថែទាំសម្រាប់ថាមពលកកើតឡើងវិញ។
- ការបង្កើតទំនាក់ទំនងរវាងគ្រឹះស្ថានសិក្សាក្នុងស្រុក និងបណ្តាញអន្តរជាតិសម្រាប់ការរៀនសូត្រពីការអនុវត្តល្អបំផុត។

សកម្មភាពនេះស្ថិតនៅក្នុងផែនការការងាររបស់គម្រោង **ខ្លេស៊ីដ្រា** (CLESIDRA) ក្នុងចំណុច WP4 (A4.4)

## អាទិភាពលេខ 2

DRAFT

A.2.1៖ **អភិបាលកិច្ច**

A2.11៖ តាមរយៈគណៈកម្មាធិការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃស្រូវដែលបានបង្កើតឡើង

- ផ្តល់អាទិភាពដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ
- ការលើកកម្ពស់ការទិញ និងការប្រើប្រាស់គ្រឿងចក្ររួម(ជាសមូហភាព) ក្នុងចំណោមអ្នកផលិត ដើម្បីកាត់បន្ថយការចំណាយ
- ការបញ្ចុះបញ្ចូលជាមួយស្ថាប័នហិរញ្ញវត្ថុ សម្រាប់ការណែនាំប្រាក់កម្ចីសម្រាប់វិស័យអាជីវកម្ម

A2.12៖ ការចរចាជាមួយរដ្ឋាភិបាលសម្រាប់៖

- គាំទ្របរិយាប័ន្នសង្គម តាមរយៈការណែនាំវិធានការផ្សះផ្សា និងមធ្យោបាយនានារវាងទំនួលខុសត្រូវក្នុងគ្រួសារ និងការងារ។ ការបង្កើនកន្លែងថែទាំសាធារណៈសម្រាប់កុមារ និងមនុស្សចាស់ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ។ ជួយសម្រួលដល់ការទទួលបានឱកាសការងារសម្រាប់មនុស្សដែលមានសមត្ថភាពផ្នែករាងកាយ និងផ្លូវចិត្តខុសៗគ្នា។ ធ្វើឲ្យប្រសើរឡើងនូវផ្លូវថ្នល់ និងការបង្កើនការដឹកជញ្ជូនតាមផ្លូវដែក និងកប៉ាល់។ ការណែនាំ/ធ្វើឲ្យប្រសើរឡើងនូវការលើកទឹកចិត្ត/កម្មវិធីគាំទ្រដល់ជីវភាពរស់នៅរបស់ក្រុមជាក់លាក់នៅក្នុងសហគមន៍។ ការណែនាំអំពីការលើកទឹកចិត្តសម្រាប់ការធ្វើការងារផ្លូវការ (មិនថាជាលក្ខណៈសមូហភាព ឬបុគ្គល) និងបទប្បញ្ញត្តិដើម្បីប្រយុទ្ធប្រឆាំងនឹងការងារក្រៅផ្លូវការ។
- ការសម្រេចបាននូវប្រព័ន្ធព័ត៌មានដែលអាចចូលប្រើប្រាស់បាន ឬទទួលបាននូវព័ត៌មានទាក់ទងនឹងវិធានការជាតិសម្រាប់ខ្សែសង្វាក់ផលិតកម្ម ការត្រួតពិនិត្យការអនុវត្តនៃផែនការជាតិសម្រាប់ខ្សែសង្វាក់ផលិតកម្ម។

A2.13៖ ការសម្រួលដល់ការធ្វើពាណិជ្ជកម្មរួមមាន៖

- កាត់បន្ថយអំណាចឈ្មួញកណ្តាល
- បង្កើតបណ្តាញទិញតាមអ៊ីនធឺណិត និងតាមទូរស័ព្ទ
- ការយល់ដឹង និងការផ្សព្វផ្សាយក្នុងចំណោមអង្គភាពសាធារណៈក្នុងការទិញផលិតផលអង្ករ/ស្រូវក្នុងស្រុក
- ការសម្របសម្រួលលទ្ធភាពក្នុងទទួលបានការធ្វើពាណិជ្ជកម្មដោយយុត្តិធម៌
- ការលើកកម្ពស់ឲ្យមានឃ្លាំងស្តុកជាសមូហភាពក្នុងចំណោមអ្នកផលិត ដើម្បីកាត់បន្ថយការចំណាយ

A2.14: គាំទ្រដល់និរន្តរភាពបរិស្ថាន សេដ្ឋកិច្ចបៃតង និងសេដ្ឋកិច្ចជារង្វង់តាមរយៈ ៖

- ជំរុញសេដ្ឋកិច្ចរាងជារង្វង់
- ការលើកកម្ពស់ទំនាក់ទំនងរវាងអ្នកផលិត និងអ្នកស្រាវជ្រាវ ដើម្បីច្នៃប្រឌិតក្នុងការអនុវត្តសេដ្ឋកិច្ចរាងជារង្វង់។
- ធ្វើកិច្ចព្រមព្រៀងជាមួយសាកលវិទ្យាល័យ និងមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) សម្រាប់ការណែនាំវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងវិស័យសេដ្ឋកិច្ចរាងជារង្វង់

A2.15៖ ការលើកកម្ពស់ការច្នៃប្រឌិតនៅក្នុងខ្សែសង្វាក់ផលិតកម្មស្រូវ ដោយយោងជាពិសេសទៅលើ៖

DRAFT

- ការស្វែងរកការគាំទ្រដើម្បីបង្កើនការស្រាវជ្រាវក្នុងវិស័យការពារគ្រាប់ពូជ ជំងឺរុក្ខជាតិ ដើម្បីការពារការខូចខាតដល់វិស័យកសិកម្ម និងការបាត់បង់ការងារ។
- ការភ្ជាប់តួអង្គនៃខ្សែសង្វាក់ផលិតកម្មស្រូវជាមួយនឹងបណ្តាញអន្តរជាតិនានា ទាក់ទងនឹងបច្ចេកវិទ្យាដើម្បីទទួលបានបច្ចេកវិទ្យាថ្មីៗ។

A2.16៖ ធ្វើឲ្យប្រសើរឡើងនូវយន្តការឆ្លើយតបសម្រាប់ការប្រឈមមុខនឹងភាពអាសន្ន រួមមាន៖ ប្រព័ន្ធជូនដំណឹង ឬផ្តល់ព័ត៌មានប្រកបដោយប្រសិទ្ធភាព និងឥតគិតថ្លៃ (WhatsApp, សង្គម, រថយន្តចល័ត, វិទ្យុ, ទូរទស្សន៍។ល។) ។ ការធ្វើតេស្តពីមុនទៅលើឥរិយាបទបុគ្គល និងសមូហភាព; ការផ្តល់ជូននូវកញ្ចប់មូនិធិសាធារណៈសម្រាប់ស្ថានភាពអាសន្ន; ការផ្តល់ជូននូវយន្តការធានារ៉ាប់រង; ការរៀបចំអង្គការដែលផ្តល់ជំនួយទៅវិញទៅមក; វត្តមានរបស់ក្រុមសង្គ្រោះស្ម័គ្រចិត្តដែលត្រូវបានបណ្តុះបណ្តាល; ការផ្តល់ជំនួយសង្គ្រោះបន្ទាន់ផ្នែកថែទាំសុខភាព; ការផ្តល់ថ្នាំពេទ្យ; ការផ្តល់កន្លែងស្នាក់នៅ និងលំនៅដ្ឋានបណ្តោះអាសន្ន; ធ្វើឲ្យមានវត្តមាននៃមូលនិធិសាធារណៈសម្រាប់ស្ថានភាពអាសន្ន និងយន្តការធានារ៉ាប់រង និងការបង្កើនភាពធន់នៃខ្សែសង្វាក់ផលិតកម្ម។

### ក.២.២៖ **ការកសាងសមត្ថភាព**

A2.21៖ ធ្វើឲ្យប្រសើរឡើងនូវជំនាញវិជ្ជាជីវៈសម្រាប់៖

- ប្រតិបត្តិករនៃបច្ចេកវិទ្យាចាប់សញ្ញាឌីជីថល និងពីចម្ងាយថ្មី; អ្នកបច្ចេកទេសជំនាញផ្នែកមនុស្សយន្ត និងស្វ័យប្រវត្តិកម្ម; អ្នកជំនាញផ្នែកបញ្ញាសិប្បនិម្មិត (AI)
- ប្រតិបត្តិករនៃបច្ចេកវិទ្យាថ្មីនៅក្នុងខ្សែសង្វាក់ផលិតកម្មស្រូវ ដូចជា ស្វ័យប្រវត្តិកម្មនៃដំណើរការផលិតស្រូវ
- បញ្ហាដូចជា៖ វិធីសាស្ត្រសាបព្រោះ, ប្រព័ន្ធធារាសាស្ត្រ, ការគ្រប់គ្រង, ការដាំដុះ និងការគ្រប់គ្រងដី, ភាពធន់នឹងសត្វល្អិត និងជំងឺ, ការប្រមូលផលទិន្នផល, ការគ្រប់គ្រងពូជ, ស្ថេរភាពនៃដំណើរការ
- ការថែទាំឧបករណ៍/សម្ភារៈ
- បញ្ហាដូចជា ការបង្កើនទិន្នផល គុណភាព រួមទាំងការកាត់បន្ថយការខាតបង់ទិន្នផល និងការតាមដានតាមរយៈការប្រើប្រាស់ជីសរីរាង្គ ជាពិសេសសម្រាប់អ្នកដែលមានសមត្ថភាពផ្សេងៗគ្នា។

A2.22៖ ការចូលរួមពីសាកលវិទ្យាល័យ ដើម្បីរួមបញ្ចូលបញ្ហាទាក់ទងនឹងការការពារបរិស្ថាននៅក្នុងកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ

### A.2.3៖ **សេវាកម្ម**

A2.31៖ ធ្វើឲ្យប្រសើឡើងនូវសេវាកម្មអាជីវកម្មសម្រាប់ការទទួលបានព័ត៌មានស្តីពី៖

- ទីផ្សារ (និន្នាការ/ការនិយម, ដៃគូប្រកួតប្រជែង, ឱកាស, របៀបធ្វើឲ្យប្រសើរឡើងនូវអំណាចចរចា, ផលិតផលណាដែលមានតម្រូវការបំផុតនៅក្នុងទីផ្សារ, របៀបបង្កើតការលក់រួម។ល។)
- ឱកាសនៃវគ្គបណ្តុះបណ្តាលដែលមានស្រាប់
- បច្ចេកវិទ្យាថ្មី
- ឱកាសទទួលបានហិរញ្ញវត្ថុ។

DRAFT

A2.32៖ ការធ្វើឲ្យប្រសើឡើងនូវសេវាកម្មទាក់ទងនឹងការបណ្តុះបណ្តាលធនធានមនុស្ស និងការជ្រើសរើសបុគ្គលិក
A2.33៖ ការធ្វើឲ្យប្រសើឡើងនូវសេវាកម្មសម្រាប់៖

- ការទទួលបានឧបករណ៍/សម្ភារៈដែលមានប្រយោជន៍សម្រាប់ខ្សែសង្វាក់ផលិតកម្ម ដោយធានានូវតម្លៃ និងគុណភាពល្អបំផុត
- ថែទាំប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់
- ការបង្កើនទិន្នផល គុណភាព រួមទាំងការកាត់បន្ថយការខាតបង់ទិន្នផល និងការតាមដាន។

A2.34៖ ការលើកកម្ពស់ការបណ្តុះគ្រាប់ពូជពូជជាក់លាក់ (ផ្ការំដួល នាងអំ ក្រចកជាស និងគ្រាប់ពូជបុរាណ/ប្រពៃណី) ក្នុងខេត្តរតនគិរី ហើយដូច្នេះកាត់បន្ថយថ្លៃដឹកជញ្ជូន។
A2.35៖ ការធ្វើឲ្យប្រសើរឡើងនូវសេវាកម្មសម្រាប់ការសម្របសម្រួលសមភាពយេនឌ័រ តាមរយៈ៖

- យុទ្ធនាការលើកកម្ពស់ការយល់ដឹងសម្រាប់ការសម្របសម្រួលសមភាពយេនឌ័រក្នុងការចែកចាយតួនាទី និងសកម្មភាពនៅក្នុងខ្សែសង្វាក់ផលិតកម្ម។
- ការពង្រឹងសមត្ថភាពរបស់ស្ត្រីក្នុងការប្រយុទ្ធប្រឆាំងនឹងការយាយី/ការបៀតបៀន (ការកំណត់(សម្គាល់) បញ្ហា/ហេតុការណ៍, ធ្វើការរាយការណ៍ ឬបរិហារ, ផ្ទៀងផ្ទាត់ប្រសិនបើវាកើតឡើងចំពោះស្ត្រីផ្សេងទៀត, ដឹងពីច្បាប់ និងសិទ្ធិរបស់ស្ត្រី, ការគាំទ្រ TVET ដើម្បីធ្វើឲ្យប្រសើរឡើងនូវការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ស្ត្រី រួមបញ្ចូលទាំងបញ្ហាដូចជា៖ ការយល់ដឹង, ការជឿជាក់លើខ្លួនឯង, គោលការណ៍សមភាពយេនឌ័រ, អំណាចចរចា, ការការពារប្រឆាំងនឹងការយាយី/ការបៀតបៀន, ព័ត៌មានអំពីឱកាសការងារ, ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ឆ្លើយតបទៅនឹងឱកាសការងារ។

A2.36៖ ធ្វើឲ្យប្រសើរឡើងនូវសេវាកម្មសម្រាប់និរន្តរភាពសង្គម តាមរយៈ៖

- ការលើកកម្ពស់សេវាកម្មសម្រាប់អាជីវកម្ម និងការងារផ្លូវការ
- គាំទ្រសហគ្រាសដែលប្រើប្រាស់ទំនួលខុសត្រូវសង្គមរបស់ពួកគេសម្រាប់ការវិនិយោគសង្គម, សម្របសម្រួលសហគ្រាសធុនតូច និងមធ្យម ដែលគ្រប់គ្រងដោយយុវជនអាយុក្រោម 35 ឆ្នាំ/សហគ្រាសធុនតូច និងមធ្យមសរុប, បង្កើតការងារសម្រាប់ជនមានពិការភាព(ផ្លូវចិត្ត និង/ឬរាងកាយ)។

## អាទិភាពលេខ៣

A.3.1៖ **អភិបាលកិច្ច**
A3.11៖ ការចរចាជាមួយរដ្ឋាភិបាលសម្រាប់៖

- ការបង្កើនកម្រិតនៃការយកចិត្តទុកដាក់ចំពោះតម្រូវការសង្គម ដោយផ្តល់អាទិភាពក្នុងការធ្វើអោយប្រសើរឡើងនូវផែនការយុទ្ធសាស្ត្រជាតិ ឬគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ។ ណែនាំពីវិធានការ និងការលើកទឹកចិត្តសម្រាប់ការងារសម្រាប់ស្ត្រី។ សម្រួលលក្ខខណ្ឌផ្លូវការសម្រាប់ការទទួលបានកម្មសិទ្ធិដីធ្លី និងផ្ទះ និងណែនាំការលើកទឹកចិត្តក្នុងការចូលប្រើប្រាស់អចលនទ្រព្យសម្រាប់ប្រជាពលរដ្ឋដែលជួបការលំបាក។

- បង្កើតស្ថាប័ននៅខេត្តរតនគិរី សម្រាប់ផលិត និងចែកចាយគ្រាប់ពូជ
- ការណែនាំអំពីការលើកទឹកចិត្តសម្រាប់ការធ្វើអោយប្រសើរឡើងនូវដំណើរការនៃខ្សែសង្វាក់ផលិតកម្ម ដូចជាការលើកទឹកចិត្តសម្រាប់ការសាងសង់ ឬការទិញឃ្លាំង, ការបង្កើតសហករណ៍, កិច្ចសហប្រតិបត្តិការ និង/ឬការចងបណ្តាញទំនាក់ទំនង។
- ការណែនាំពីយន្តការ និងកម្មវិធីហិរញ្ញវត្ថុជាក់លាក់ ដើម្បីគាំទ្រខ្សែសង្វាក់ផលិតកម្មស្រូវ និងកាត់បន្ថយអត្រាការប្រាក់សម្រាប់យន្តការដែលមានស្រាប់។ ជាពិសេស ណែនាំការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់៖ ការចាប់ផ្តើមអាជីវកម្ម, ការទិញបច្ចេកវិទ្យាថ្មី, ការផលិតស្រូវ/អង្ករមិនថាជាលក្ខណៈបុគ្គល សមាគម និងសហករណ៍។
- ការធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃគោលនយោបាយ និងបទប្បញ្ញត្តិសាធារណៈស្តីពីនិរន្តរភាពបរិស្ថាន និងសេដ្ឋកិច្ចបៃតង តាមរយៈការកាត់បន្ថយការបំពុល (ខ្យល់ ទឹក ដី និងសំឡេង) ការកំណត់កម្រឹងការបំភាយឧស្ម័ន កាត់បន្ថយនីតិវិធីការិយាធិបតេយ្យ និងពេលវេលាដើម្បីទទួលបានវិញ្ញាបនប័ត្របញ្ជាក់ពីផលិតកម្មស្រូវសរីរាង្គ។ ធានាការអនុវត្តផែនការដែលមានស្រាប់សម្រាប់ការអភិវឌ្ឍខ្សែសង្វាក់ផលិតកម្ម។ ការណែនាំវិធានការដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ និងការបំពុល (ដូចជាប្រព័ន្ធគ្រប់គ្រងការបំពុលក្នុងខេត្តរតនគិរី) និងបង្កើតហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដើម្បីជៀសវាងការបំពុលទឹក និងខ្យល់។
- សម្របសម្រួលការវិភាគដី វាយតម្លៃសមាសភាពនៃសារធាតុសរីរាង្គ និងមិនមែនសរីរាង្គ តាមរយៈឧបករណ៍ត្រឹមត្រូវ។

A3.12៖ ធ្វើកិច្ចព្រមព្រៀងជាមួយស្ថាប័នហិរញ្ញវត្ថុដែលកាត់បន្ថយការលំបាកនៃការទទួលបានឥណទាន (ការធានាការប្រាក់ រយៈពេលអនុគ្រោះ ការធានារ៉ាប់រង។ល។)

A3.13៖ ធ្វើកិច្ចព្រមព្រៀងជាមួយសាកលវិទ្យាល័យ និងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សម្រាប់ការរៀបចំជំនាញវិជ្ជាជីវៈថ្មីៗ។

A3.14៖ លើកកម្ពស់សមភាពយេនឌ័រ និងបរិយាប័ន្នសង្គម តាមរយៈ៖

- រដ្ឋធម្មនុញ្ញ(ច្បាប់/សិទ្ធិ)ស្តីពីសហជីពកម្មករស្ត្រី ។
- ការបង្កើតប្រព័ន្ធទូរស័ព្ទ សម្រាប់រាយការណ៍ពីការយាយី/ការបៀតបៀន ដែលគ្រប់គ្រងដោយសមាគមស្ត្រី។
- ការសម្របសម្រួលអាជីវកម្មក្រៅផ្លូវការ តាមរយៈការដាក់សម្ពាធដល់រដ្ឋាភិបាលក្នុងការកាត់បន្ថយបទប្បញ្ញត្តិការិយាធិបតេយ្យ និងការផ្តល់នូវការលើកទឹកចិត្ត

A3.15៖ ធ្វើកិច្ចព្រមព្រៀងជាមួយសាកលវិទ្យាល័យ ស្ថាប័នស្រាវជ្រាវ និង TVET សម្រាប់៖

- ការដាក់ចេញនូវវគ្គបណ្តុះបណ្តាលថ្មីទាក់ទងនឹងការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្មស្រូវ
- ជំរុញការស្រាវជ្រាវលើបច្ចេកវិជ្ជាថ្មីដែលបានអនុវត្តចំពោះខ្សែសង្វាក់ផលិតកម្មស្រូវ

A3.2: **ការកសាងសមត្ថភាព**

A3.21៖ ធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់សហគ្រិនដូចជា៖

DRAFT

- ធ្វើផែនការអាជីវកម្មសម្រាប់អាចស្នើសុំហិរញ្ញវត្ថុ/ឥណទានពីធនាគារធនាគារ
- ការចាប់ផ្តើមអាជីវកម្ម
- ការធ្វើទីផ្សារ និងពាណិជ្ជកម្ម

A3.22៖ ការលើកកម្ពស់សមភាពយេនឌ័រ តាមរយៈ៖

- ផ្តល់ការកសាងសមត្ថភាពដល់ស្ត្រីដើម្បីអាចឲ្យពួកគេអាចធ្វើការក្នុងខ្សែសង្វាក់ផលិតកម្មស្រូវ។
- ការកសាងសមត្ថភាពដែលអនុគ្រោះ(ជួយជម្រុញ)ដល់ស្ត្រីឲ្យទទួលបានតំណែងជាអ្នកដឹកនាំ និងចូលរួមក្នុងស្ថាប័នតំណាង (ឧទាហរណ៍៖ ក្រុមកម្មករ សហជីព។ល។)
- ការកសាងសមត្ថភាពទៅកាន់ក្រុមហ៊ុននានា ដើម្បីដាក់ចេញនូវវិធានការសម្រាប់សមភាពយេនឌ័រ
- ពង្រឹងសមត្ថភាពរបស់ស្ត្រីក្នុងការប្រយុទ្ធប្រឆាំងនឹងវិសមភាពយេនឌ័រ (ការកំណត់(សម្គាល់)បញ្ហា/ហេតុការណ៍, ការរាយការណ៍ពីបញ្ហា, ផ្ទៀងផ្ទាត់ប្រសិនបើវាកើតឡើងចំពោះស្ត្រីផ្សេងទៀត, ដឹងពីច្បាប់ និងសិទ្ធិរបស់ស្ត្រី)
- វគ្គបណ្តុះបណ្តាលការងារទៅកាន់ស្ត្រីអំពីខ្សែសង្វាក់ផលិតកម្មស្រូវ
- វគ្គបណ្តុះបណ្តាលស្តីពីការចាប់ផ្តើមអាជីវកម្ម ទៅកាន់ស្ត្រី និងយុវជន
- ការបង្ហាញពីការអនុវត្តល្អបំផុតនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ ឬគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ

A3.23៖ ការធ្វើឲ្យប្រសើរឡើងនូវនិរន្តរភាពបរិស្ថាន តាមរយៈ៖

- ការបណ្តុះបណ្តាលដល់អង្គការ និង/ឬស្ថាប័នដែលប្តេជ្ញាចិត្តចំពោះនិរន្តរភាពបរិស្ថាន និងសេដ្ឋកិច្ចបៃតង។
- ការកសាងសមត្ថភាពទៅកាន់អ្នកផលិតដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពល និងទឹក លើកកម្ពស់ការប្រើប្រាស់ថាមពលកកើតឡើងវិញ និងការអនុវត្តល្អបំផុតក្នុងការគ្រប់គ្រងកាកសំណល់ ដើម្បីជៀសវាងការបំពុលដី និងទឹក ។
- ការកសាងសមត្ថភាពលើវិធានការទប់ទល់ដែលអាចត្រូវបានអនុវត្តដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដូចជា៖ សមត្ថភាពក្នុងការផលិតទំនិញដែលត្រូវការក្នុងគ្រាមានអាសន្នស្បៀងអាហារបន្ទាប់ពីគ្រោះមហន្តរាយ, លទ្ធភាពនៃការប្រើប្រាស់កម្មករដើម្បីគាំទ្រផលិតកម្មផ្សេងទៀត; ការលុបបំបាត់ការបំពុលកាកសំណល់ (ផលិតផលគីមី, ផលិតផលដែលមានកាកសំណល់ដែលមិនអាចបំប្លែងបាន); ការកាត់បន្ថយថាមពលពីប្រភពមិនកកើតឡើងវិញ និងការបំភាយឧស្ម័នកាបូនិក ($CO_2$); គំរូដាំដុះបែបសរីរាង្គ និងការដាំដុះបែបកសិអេកូឡូស៊ី ផ្អែកលើបែបផែនផ្សេងៗ ឬភាពចម្រុះ។

A3.24៖ ការលើកកម្ពស់និរន្តរភាពសង្គម និងបរិស្ថាន តាមរយៈយុទ្ធនាការលើកកម្ពស់ការយល់ដឹងលើបញ្ហាដូចខាងក្រោម៖

- សមភាពយេនឌ័រ និងសារៈសំខាន់នៃលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានការងារ ជាពិសេសទាក់ទងនឹងការចូលរួមរបស់ស្ត្រីចំពោះដំណើរការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្ម និងវិធីប្រយុទ្ធប្រឆាំងនឹងទំនៀមទម្លាប់ប្រពៃណីដែលមានចរិតរើសអើង/រំលោភសិទ្ធិ (ឧ. កូនស្រី/មនុស្សស្រីមិនគួររៀនច្រើនពេកទេ, កូនប្រុសស្រីគ្មានសិទ្ធិរើសគូស្រករដោយខ្លួនឯងទេ ។ល។)

DRAFT

- ឱកាសអាជីវកម្ម និងការងារ ដែលផ្តល់អាទិភាពដល់ជនពិការ ស្ត្រី និងយុវជន ដែលបង្កើតឡើងដោយការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្មនៅក្នុងសមាសធាតុទាំងអស់របស់វា។
- យុទ្ធនាការលើកកម្ពស់ការយល់ដឹងជាមួយសហគ្រិន រួមទាំងការបៀតបៀនស្ត្រីដែលត្រូវបានហាមឃាត់ និងការធ្វើទុក្ខបុកម្នេញទៅលើស្ត្រីដែលជាបទប្បញ្ញត្តិរបស់ក្រុមហ៊ុន។
- សារៈសំខាន់នៃការអភិរក្ស និងការកែលម្អគុណភាពដី ជាពិសេសតាមរយៈការប្រើប្រាស់ជីសរីរាង្គ។
- យុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់ធនធានទឹករយៈពេលវែងប្រកបដោយប្រសិទ្ធភាព។
- ហានិភ័យដែលបណ្តាលមកពីការបំពុលដី ទឹក និងខ្យល់ និងវិធានការដែលត្រូវអនុវត្តដើម្បីពារការ។

A3.3 **សេវាកម្ម**

A3.31៖ ការលើកកម្ពស់ និងធ្វើឲ្យប្រសើរឡើងនូវសេវាកម្មអាជីវកម្ម ជាពិសេសសេវាកម្មទៅកាន់សហគ្រិន ដើម្បីបង្កើនការប្រកួតប្រជែងនៃខ្សែសង្វាក់ផលិតកម្ម តាមរយៈ៖

- សេវាត្រួតពិនិត្យគុណភាពដី
- សេវាជំនួយលើការសាបព្រោះ, ប្រព័ន្ធធារាសាស្ត្រ, ការគ្រប់គ្រង, ភាពធន់នឹងសត្វល្អិត និងជំងឺ, ការប្រមូលផល, ការគ្រប់គ្រងពូជ, ស្តេរភាពការអនុវត្ត ។ល។ ជាពិសេស សេវាបច្ចេកទេសលើការដាំដុះ និងការគ្រប់គ្រងដី។
- សេវា អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET)
- សេវាកម្មគាំទ្រដើម្បីបង្កើតសហករណ៍ បណ្តាញទំនាក់ទំនង សម្ព័ន្ធភាព/សមាគម
- សេវាកម្មបើក/ចាប់ផ្តើមអាជីវកម្ម
- សេវាសម្រាប់ណែនាំបច្ចេកវិទ្យាថ្មីៗ
- សេវាគាំទ្រជាក់លាក់ដើម្បីបង្កើតជាសហគ្រិនស្ត្រី
- លើកកម្ពស់ការបង្កើតសេវាត្រួតពិនិត្យគុណភាព និងវិញ្ញាបនប័ត្រ
- ធ្វើឲ្យប្រសើរឡើងនូវសេវាព័ត៌មាននៅលើបណ្តាញក្នុងស្រុក តំបន់ ជាតិ អន្តរជាតិ ដែលមានស្រាប់

A3.32៖ ការកសាងបណ្តាញទំនាក់ទំនងជាមួយក្រុមហ៊ុន ឬអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាកម្ម និងផលិតផលក្នុងដំណើរការដាំដុះ (សម្រាប់គោលបំណងកសិកម្ម) ក្នុងតម្លៃសមរម្យ/ទាប)

A3.33៖ សម្របសម្រួលសេវាត្រួតពិនិត្យ/គ្រប់គ្រងការបំពុលក្នុងខេត្តរតនគិរី

## <u>ការសំយោគគោលការណ៍ណែនាំជាយុទ្ធសាស្ត្រសំខាន់ៗ</u>

DRAFT

ប្រអប់ខាងក្រោមបង្ហាញពីការសំយោគគោលការណ៍ណែនាំជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្មស្រូវសម្រាប់អាទិភាពលេខ ១៖

**ប្រអប់ទី ២. ការសំយោគគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្មស្រូវសម្រាប់អាទិភាពលេខ ១**

(ប្រភព ILS LEDA)

| | កម្រិតខ្សែសង្វាក់តម្លៃច្រើន | កម្រិតខ្សែសង្វាក់តម្លៃ |
|---|---|---|
| **អភិបាលកិច្ច** | បង្កើតវេទិកា PLASED (វេទិកាសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព) ដែលជាយន្តការសម្រាប់ពង្រឹងកិច្ចសន្ទនាសង្គម និងរក្សាបាននូវអត្ថប្រយោជន៍ប្រកួតប្រជែង និងបង្កើតការងារ។ | បង្កើតគណកម្មាធិការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្មស្រូវ ដោយផ្អែកលើអ្នកចូលរួមក្រុមស្នូល និងជាក្រុមរងនៃវេទិកា ផ្លាសិដ (PLASED) |
| | | បង្កើតក្រុមការងារជាមួយក្រសួងសេដ្ឋកិច្ច និងក្រសួងកសិកម្ម និងអាជ្ញាធរសាធារណៈពាក់ព័ន្ធផ្សេងទៀត ដើម្បី៖<br>• ការណែនាំអំពីការលើកទឹកចិត្ត ឬវិធានការណ៍ថ្នាក់ជាតិដើម្បីគាំទ្រខ្សែសង្វាក់ផលិតកម្ម<br>• ការកែលម្អប្រព័ន្ធធារាសាស្ត្រ; សេដ្ឋកិច្ចបៃតង និងនិរន្តរភាពបរិស្ថាន |
| | | សម្របសម្រួលពាណិជ្ជកម្ម |
| **សេវាកម្ម** | បង្កើត COSS (ប្រព័ន្ធសេវាទូលំទូលាយ) សម្រាប់ការផ្តល់សេវាសេដ្ឋកិច្ចសង្គមប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល | ការកែលម្អសេវាកម្ម ដោយផ្តល់អាទិភាពចំពោះ ៖ ការធ្វើទីផ្សារ និងការធ្វើពាណិជ្ជកម្ម, សេវាកម្មចាប់ផ្តើមអាជីវកម្ម; ជាពិសេសសម្រាប់ការចាប់ផ្តើម/បើកសហគ្រាសថ្មីសម្រាប់ផលិតផលិតផលស្រូវ និងផលិតផលកែចេញច្នៃពីស្រូវ |
| | | ធ្វើឲ្យប្រសើឡើងនូវសេវាកម្មសម្រាប់និរន្តរភាពបរិស្ថាន |
| | ធ្វើឲ្យប្រសើឡើងនូវសេវាកម្មអាជីវកម្ម និងលទ្ធភាពទទួលបានសេវាកម្មទាំងនោះ | គាំទ្រដល់ការផលិតផលិតផលរង (ផលិតផលកែច្នៃពីស្រូវ) |
| **ការកសាងសមត្ថភាព** | កសាងសមត្ថភាពលើការគ្រប់គ្រងអាជីវកម្ម និងការធ្វើផែនការអាជីវកម្ម ដែលមានប្រយោជន៍ផងដែរសម្រាប់ការសំណើ | ពង្រឹងជំនាញវិជ្ជាជីវៈ ដើម្បីជំរុញការផលិតពូជជាក់លាក់ និងផលិតផលិតផលស្រូវ និងផលិតផលកែចេញច្នៃពីស្រូវ |

DRAFT

| | | |
|---|---|---|
| | ថវិកា និងឥណទាន | ធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់សហគ្រិន |
| | | អនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹង (អាចតាមរយៈសន្និសីទសហគមន៍) ដើម្បីបង្កើននិរន្តរភាពបរិស្ថាន |

ប្រអប់ខាងក្រោមបង្ហាញពីការសំយោគគោលការណ៍ណែនាំយុទ្ធសាស្ត្រអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្មស្រូវសម្រាប់អាទិភាពលេខ ២៖

**ប្រអប់ទី ៣. ការសំយោគគោលការណ៍ណែនាំស្ដីពីការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្មស្រូវសម្រាប់អាទិភាពលេខ ២**

(ប្រភព ILS LEDA)

| | កម្រិតខ្សែសង្វាក់តម្លៃច្រើន | កម្រិតខ្សែសង្វាក់តម្លៃ |
|---|---|---|
| **អភិបាលកិច្ច** | សម្រេចបាននូវសេវាកម្មដែលឆ្លើយតបទៅនឹងតម្រូវការការងារ និងការផ្គត់ផ្គង់ការងារ | បញ្ចុះបញ្ចូលជាមួយរដ្ឋាភិបាលសម្រាប់ការសម្រេចបាននូវហេដ្ឋារចនាសម្ព័ន្ធឆ្លាតវៃ៖ ការសម្របសម្រួលលទ្ធភាពទទួលបានមូលនិធិ, ការបង្កើនការស្រាវជ្រាវលើបច្ចេកវិទ្យាថ្មីៗ, និងការទទួលយកការលើកទឹកចិត្តសម្រាប់អាជីវកម្មដែលបង្កើនការងារ។ |
| | | ពង្រឹងនិរន្តរភាពបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ |
| **សេវាកម្ម** | ធ្វើឲ្យប្រសើរឡើងនូវសេវាកម្មសម្រាប់ការចាប់ផ្ដើមអាជីវកម្ម | ធ្វើឲ្យប្រសើរឡើងនូវសេវាកម្មអាជីវកម្ម និងលទ្ធភាពទទួលបានសេវាទាំងនោះ ជាពិសេសសេវាត្រួតពិនិត្យគុណភាព ការត្រួតពិនិត្យគុណភាពដី និងសេវាកម្មដឹកជញ្ជូន |
| | ធ្វើឲ្យប្រសើរឡើងនូវសេវាកម្មសម្រាប់និរន្តរភាពបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (សេដ្ឋកិច្ចរាងជារង្វង់) | គាំទ្រក្នុងការផលិតផលិតផលរង (ផលិតផលកែច្នៃពីស្រូវ) |
| | ការសម្រួលដល់លទ្ធភាពទទួលបានប្រាក់កម្ចី/ឥណទាន | |
| | | ធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់តួអង្គក្នុងស្រុកដើម្បីទទួលបានព័ត៌មានអំពីនិន្នាការ/ការនិយមនៃតម្រូវការទីផ្សារ |

DRAFT

| | | |
|---|---|---|
| **ការកសាងសមត្ថភាព** | | ជំរុញកសិករក្នុងការរៀបចំសកម្មភាពរបស់ពួកគេជាផ្លូវការ |
| | | កសាងសមត្ថភាពលើការការពារបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់បម្រែបម្រួលអាកាសធាតុ តាមរយៈការបង្ហាញពីការអនុវត្តល្អបំផុត |
| | | កសាងសមត្ថភាពលើ "របៀបគ្រប់គ្រងកិច្ចសហប្រតិបត្តិការក្នុងចំណោមអ្នកផលិត" |
| | | កសាងសមត្ថភាពលើជំនាញវិជ្ជាជីវៈដែលត្រូវការ ដោយការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្មស្រូវ |

DRAFT